# កិច្ចព្រមព្រៀងសហប្រតិបត្តិការ
# រវាង
# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម
# ស្តីពី
# នីតិវិធីប្រតិបត្តិបទដ្ឋាន ក្នុងការកំណត់អត្តសញ្ញាណ
# និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយសារអំពើជួញដូរ

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម (ដែលតទៅនេះ កំណត់ហៅថា ភាគីទាំងពីរ)។

យោងមាត្រា ១១, ១២ និង ១៣ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ ដែលបានចុះហត្ថលេខានៅថ្ងៃទី១០ ខែ តុលា ឆ្នាំ២០០៥ នៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

យោងពិធីសារ ស្តីពីការបង្ការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោស អំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ដែលបំពេញបន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្ម ដែលមានអង្គការចាត់តាំង និងមានលក្ខណៈឆ្លងប្រទេស។

យោងសន្ធិសញ្ញា ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក ក្នុងរឿងព្រហ្មទណ្ឌ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ដែលបានចុះហត្ថលេខា នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ នៅទីក្រុងកូឡាឡាំពួរ និងអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ (ខមមីត) ដែលបានចុះហត្ថលេខា នៅថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៤ នៅទីក្រុងយ៉ាន់ហ្គូន សហភាពមីយ៉ាន់ម៉ា។

ក្នុងស្មារតីនៃកិច្ចសហប្រតិបត្តិការ សាមគ្គីភាព និងផ្តោលើជនរងគ្រោះ ដើម្បីផ្តល់ការគាំទ្រដ៏ប្រសើរបំផុតដល់ជនរងគ្រោះដោយសារអំពើជួញដូរ។

ក្នុងស្មារតីមនុស្សធម៌ និងភាពស្របច្បាប់ដោយឡែកនៃប្រទេសនីមួយៗ:

01.04.2016

បានឯកភាពបង្កើតនីតិវិធីប្រតិបត្តិបទដ្ឋាន ក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយសារអំពើជួញដូរ ដែលមានខ្លឹមសារពិស្តារដូចតទៅៈ

**មាត្រា១ៈ លក្ខណៈវិនិច្ឆ័យក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយសារអំពើជួញដូរ**

ក-ជនរងគ្រោះដោយសារអំពើជួញដូរ (ដែលតទៅនេះកំណត់ហៅថា ជនរងគ្រោះ) គឺជនទាំងឡាយណាដែលត្រូវបានគេជ្រើសរើសដឹកជញ្ជូន ផ្ទេរដោយខុសច្បាប់ ពីវៀតណាមមកកម្ពុជា ឬពីកម្ពុជាទៅវៀតណាម ដោយមធ្យោបាយគម្រាមកំហែង ប្រើប្រាស់កម្លាំងចាប់ពង្រត់ បោកបញ្ឆោត ការរំលោភបំពានដោយប្រើអំណាច ឬទម្រង់ផ្សេងទៀត នៃការបង្ខិតបង្ខំក្នុងគោលបំណងធ្វើអាជីវកម្មដើម្បីកេងប្រវ័ញ្ច។

ខ-ជនរងគ្រោះត្រូវបានកំណត់ឡើងដោយផ្អែកលើមូលដ្ឋានដូចខាងក្រោមៈ

- ឯកសារ ភស្តុតាង ដែលបានផ្តល់ដោយភាគីទាំងពីរ
- ចម្លើយ និងភស្តុតាង ដែលផ្តល់ដោយភាគីទាំងពីរ
- ចម្លើយ និងភស្តុតាងដែលផ្តល់ដោយជនរងគ្រោះ
- លទ្ធផលនៃការផ្ទៀងផ្ទាត់ដោយនគរបាល ឆ្មាំព្រំដែនវៀតណាម និងក្រសួងមហាផ្ទៃនិងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កម្ពុជា
- ចម្លើយរបស់អ្នកដែលបានប្រព្រឹត្តអំពើជួញដូរមនុស្ស
- ព័ត៌មានដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល ពាក់ព័ន្ធក្នុងការជួយសង្គ្រោះ
- ព័ត៌មានដែលបានមកពីប្រភពផ្សេងៗ។

**មាត្រា២- ស្ថាប័នបង្គោលសម្រាប់ទទួលព័ត៌មាន**

ក-ភាគីវៀតណាមៈ នាយកដ្ឋានគ្រប់គ្រងអន្តោប្រវេសន៍-ក្រសួងសន្តិសុខសាធារណៈ ឬស្ថាប័នគ្រប់គ្រងអន្តោប្រវេសន៍ថ្នាក់ខេត្ត ដែលចំណុះក្រសួងសន្តិសុខសាធារណៈ។

ខ-ភាគីកម្ពុជាៈ នាយកដ្ឋានសុខុមាលភាពសង្គម (ការិយាល័យប្រឆាំងការជួញដូរមនុស្សនិងសមាហរណកម្ម) នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត ដែលផ្តល់អំណាចដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា៣- ជំហាន និងនីតិវិធីនៃការផ្ទៀងផ្ទាត់ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ**

នៅពេលដែលអាជ្ញាធរមានសមត្ថកិច្ច នៃភាគីណាមួយបានរកឃើញ ឬសង្គ្រោះបានជនរងគ្រោះណាម្នាក់ត្រូវអនុវត្តជំហានដូចខាងក្រោមៈ

ក-ជនរងគ្រោះនឹងត្រូវបានផ្ទេរទៅមណ្ឌលគាំទ្រ ដែលនៅជិតបំផុត និងផ្តល់សេវាចាំបាច់ដល់ពួកគេ ដូចជាជំនួយផ្នែកចិត្តសាស្ត្រ ការថែទាំខុសភាព ការស្នាក់នៅ និងហូបចុក នៅពេលកំពុងរង់ចាំលទ្ធផល នៃដំណើរការផ្ទៀងផ្ទាត់និងការកំណត់អត្តសញ្ញាណ។

ខ-នៅក្នុងមណ្ឌលគាំទ្រជនរងគ្រោះ។

ស្ថាប័នមានសមត្ថកិច្ចក្នុងប្រទេសនីមួយៗជាអ្នកទទួលខុសត្រូវលើការបើកសំណុំករណីជាបឋម តាមទម្រង់ដែលភាគីទាំងពីរបានឯកភាព និងធ្វើទំនាក់ទំនងជាមួយស្ថាប័នបង្គោលនៃភាគីម្ខាងទៀត ដើម្បីស្នើសុំធ្វើការផ្ទៀងផ្ទាត់សញ្ជាតិ និងកំណត់អត្តសញ្ញាណរបស់ជនរងគ្រោះ

-ស្ថាប័នបង្គោលនៃភាគីទាំងពីរ (ដូចបានកំណត់ក្នុងមាត្រា២) នឹងសហការជាមួយស្ថាប័នពាក់ព័ន្ធរបស់ប្រទេសសាម៉ី ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ ផ្ទៀងផ្ទាត់សញ្ជាតិរបស់ជនរងគ្រោះនិងស្វែងរកក្រុមគ្រួសារជនរងគ្រោះ។

-ដោយពីទទួលបានសំណើរជាផ្លូវការ ភាគីដែលត្រូវបានស្នើ ត្រូវរៀបចំដំណើរការផ្ទៀងផ្ទាត់អោយបានឆាប់បំផុត ហើយលទ្ធផលស្វែងរកគ្រួសារទោះបីជាឃើញ ឬមិនឃើញ ត្រូវផ្តល់ព័ត៌មានត្រឡប់ទៅភាគីម្ខាងទៀត លាយលក្ខណ៍អក្សរជាផ្លូវការ ក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹម ៣០ថ្ងៃ នៃការងារ ហើយត្រូវផ្តល់ចំលើយពីការយល់ព្រម ឬមិនយល់ព្រមទទួលយកជនរងគ្រោះ

ឃ-សំណុំឯកសារករណីជនរងគ្រោះរួមមានៈ

ទម្រង់ប្រកាសស្ម័គ្រចិត្តវិលត្រឡប់ សម្រាប់ជនរងគ្រោះដោយសារការជួញដូរ ដោយភ្ជាប់លេខកូដករណីដែលត្រូវប្រើប្រាស់រួមដោយភាគីទាំងពីរ។

- ប្រវត្តិរូបសង្ខេបរបស់ជនរងគ្រោះ (ដោយភ្ជាប់ជាមួយរូបថត)
- ស្នាមក្រយៅដៃរបស់ជនរងគ្រោះ
- លិខិតស្នើសុំ ដើម្បីឲ្យភាគីទទួលធ្វើការផ្ទៀងផ្ទាត់ និងទទួលយកជនរងគ្រោះ
- ក្នុងករណីដែលជនរងគ្រោះមានបញ្ហាសុខភាព ភាគីប្រគល់ត្រូវផ្តល់ព័ត៌មានជូនភាគីទទួលជាមុន។

ង- ការផ្ទេរសំណុំឯកសារៈ

- សំណុំឯកសារផ្ទៀងផ្ទាត់ និងកំណត់អត្តសញ្ញាណជនរងគ្រោះ ត្រូវតែបញ្ជូនតាមរយៈបេសកកម្មការទូត ស្ថាប័នតំណាងការបរទេស ឬស្ថានកុងស៊ុល របស់ប្រទេសស្នើសុំ ដើម្បីបញ្ជូនបន្តទៅស្ថាប័នបង្គោលអនុវត្ត។
- លិខិតស្នើសុំផ្ទៀងផ្ទាត់ និងទទួលជនរងគ្រោះ ត្រូវប្រើប្រាស់ជា ២ភាសា គឺភាសាខ្មែរ និងភាសាវៀតណាម។

**មាត្រា ៤-ជំហាន និងនីតិវិធីនៃការប្រគល់ និងការទទួលជនរងគ្រោះ**

ក- ក្រោយពីការយល់ព្រមទទួលយកជនរងគ្រោះ ក្នុងរយៈពេល ៩ថ្ងៃនៃការងារ ស្ថាប័នបង្គោលនៃភាគីទាំងពីរនឹងឯកភាពលើផែនការប្រគល់ ដោយរួមមានបញ្ជីឈ្មោះជនរងគ្រោះ ដែលត្រូវធ្វើការប្រគល់ ពេលវេលាប្រគល់ មធ្យោបាយដឹកជញ្ជូន និងច្រកទ្វារព្រំដែនអន្តរជាតិ ដើម្បីទទួលយកជនរងគ្រោះ។

ខ-បេសកកម្មការទូត ស្ថាប័នតំណាងការបរទេស ឬស្ថានកុងស៊ុលនៃភាគីទទួល ត្រូវចេញលិខិតបើកផ្លូវ (Laissez-Passer) ឲ្យជនរងគ្រោះ ហើយអាជ្ញាធរគ្រប់គ្រងអន្តោប្រវេសន៍នៃភាគីប្រគល់ ទទួលខុសត្រូវចំពោះផ្តល់ទិដ្ឋាការចេញ (Exit Pass) ឲ្យជនរងគ្រោះវិលត្រឡប់ទៅប្រទេសដើមវិញ។

គ-ស្ថាប័នបង្គោលនៃភាគីទទួល ជានាទទួលខុសត្រូវចំពោះកិច្ចសហការជាមួយភ្នាក់ងារពាក់ព័ន្ធផ្សេងៗទៀត ដើម្បីរៀបចំការទទួលជនរងគ្រោះ និងផ្តល់ការគាំទ្របឋមដល់ជនរងគ្រោះ។

ឃ- នីតិវិធីក្នុងការប្រគល់ និងទទួលជនរងគ្រោះនៅច្រកទ្វារព្រំដែនៈ

- ស្ថាប័នបង្គោលនៃប្រទេសទាំងពីរ មានភារកិច្ចផ្លាស់ប្តូរព័ត៌មានជាក់ស្តែងរួមមានទាំងការបញ្ជាក់អំពីពេលវេលា និងទីកន្លែងសម្រាប់ទទួលយកជនរងគ្រោះ។ ទីកន្លែងទទួលយកជនរងគ្រោះ គួរតែនៅច្រកទ្វារព្រំដែនអន្តរជាតិ ដែលនៅជិតកន្លែងស្នាក់នៅបណ្តោះអាសន្នសម្រាប់ជនរងគ្រោះ ដែលទទួលបានការឧបត្ថម្ភគាំទ្រ។ ស្ថាបន័បង្គោលត្រូវបានលើកទឹកចិត្ត ក្នុងការបង្កើនកិច្ចសហការជាមួយបណ្តាអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសរបស់ខ្លួន ដើម្បីជំរុញអោយបានឆាប់រហ័សនូវសំណើរការប្រគល់និងទទួលយកជនរងគ្រោះ។

+ ជំហាននានាក្នុងការប្រគល់ និងទទួលយកជនរងគ្រោះ

+ ជំហានទី១: ស្ថាប័នបង្គោលនៃភាគីប្រគល់សហការជាមួយស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអមដំណើរជនរងគ្រោះទៅកាន់ចំណុចគោលដៅច្រកទ្វារព្រំដែនអន្តរជាតិ ដែលជាកន្លែងរៀបចំពិធីប្រគល់និងទទួលយកជនរងគ្រោះ។

+ ជំហានទី២: ស្ថាប័នបង្គោលនៃភាគីទទួល មានភារកិច្ចទទួលយកនូវរាល់សំណុំឯកសារដែលពាក់ព័ន្ធទាំងអស់ បន្ទាប់មកត្រូវធ្វើការបញ្ជាក់ និងផ្ទៀងផ្ទាត់ ដើម្បីកំណត់ឲ្យច្បាស់ពីកិនភាគជនរងគ្រោះតាមបញ្ជីឈ្មោះ ដែលបានយល់ព្រម និងចុះហត្ថលេខាដោយផ្ទាល់លើកំណត់ហេតុប្រគល់និងទទួលយកជនរងគ្រោះ។

+ ជំហានទី៣៖ អាជ្ញាធរមានសមត្ថកិច្ចដែលនៅខាងភាគីទទួល នឹងនាំជនរងគ្រោះទៅកាន់លំនៅដ្ឋាន ឬមណ្ឌលគាំទ្រជនរងគ្រោះយោងទៅលើច្បាប់ និងគោលនយោបាយរបស់ប្រទេសទទួល។

-ឯកសារ ដែលត្រូវផ្លាស់ប្តូរគ្នារវាងភាគីទាំងពីរមានៈ

+ បញ្ជីរាយនាមជនរងគ្រោះ

+ លិខិតបើកផ្លូវ ដែលមានទិដ្ឋាការចេញ សម្រាប់ជនរងគ្រោះបានវិលត្រឡប់ទៅមាតុភូមិវិញ (ដូចបានចែងក្នុងមាត្រា ៤ ចំណុច ខ)

+ កំណត់ហេតុប្រគល់ និងទទួលយកជនរងគ្រោះ

+ ឯកសារសំគាល់អត្តសញ្ញាណជនរងគ្រោះ(ប្រសិនបើមាន)

+ សំណុំឯកសារកំណត់អត្តសញ្ញាណជនរងគ្រោះ

+ សំណុំឯកសារសុខភាពរបស់ជនរងគ្រោះ។

**មាត្រា៥៖ ក្រុមការងារ**

យោងតាមកិច្ចព្រមព្រៀងនេះ ស្ថាប័នបង្គោលនៃភាគីនីមួយៗ ត្រូវបង្កើតក្រុមការងារ ដែលមានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោមៈ

ក-ទទួលនិងវិភាគព័ត៌មានពាក់ព័ន្ធនឹងការផ្ទៀងផ្ទាត់ ការកំណត់អត្តសញ្ញាណ ការទទួលយក និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ។

ខ- បង្កើតផែនការសកម្មភាព សម្រាប់អនុវត្តកិច្ចព្រមព្រៀងនេះ

គ- គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តកិច្ចព្រមព្រៀង របស់ស្ថាប័នដែលមានការពាក់ព័ន្ធនៃប្រទេសនីមួយៗ។

ឃ-សហការដោះស្រាយរាល់បញ្ហាដែលអាចកើតមានឡើង នៅក្នុងអំឡុងពេលដំណើរការអនុវត្តកិច្ចព្រមព្រៀងនេះ។ ក្នុងករណីមិនមានការ ឯកភាពគ្នា ក្រុមការងារនេះ ត្រូវរាយការណ៍ជូនទៅស្ថាប័នបង្គោល ដើម្បីស្នើទៅរដ្ឋាភិបាលនៃប្រទេសសាម៉ី ពិភាក្សារកដំណោះស្រាយ។

ង-ក្រុមការងារនឹងជួបប្រជុំទ្វេភាគី នៅពេលណាមានការចាំបាច់។ ពេលវេលានិងទីកន្លែង នៃការប្រជុំនិងត្រូវបានពិភាក្សា និងឯកភាពពីស្ថាប័នបង្គោល នៃភាគីទាំងពីរ។

**មាត្រា៦៖ ការអនុវត្ត**

ក-កិច្ចព្រមព្រៀងនេះ អាចត្រូវបានកែប្រែ ឬក៏បំពេញបន្ថែមដោយផ្អែកលើការឯកភាពជាលាយលក្ខណ៍អក្សររបស់ភាគីទាំងពីរ។ រាល់មាត្រា ចំណុចដែលភាគីទាំងពីរបានឯកភាព កែប្រែ បំពេញបន្ថែមត្រូវចាត់ទុកជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ត្រូវមានសុពលភាពនៅពេលដែលបានទទួលនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបញ្ជាក់ថា ភាគីទាំងពីរបានបញ្ចប់នូវនីតិវិធីផ្ទៃក្នុងខាងផ្លូវច្បាប់ សម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។

កិច្ចព្រមព្រៀងនេះ មានសុពលភាពស្របគ្នានឹងសុពលភាពនៃកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ ដែលបានចុះហត្ថលេខានៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ នៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

គ-កិច្ចព្រមព្រៀងនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៩ជាពីរច្បាប់ដើមក្នុងមួយច្បាប់មានបីភាសាគឺ ភាសាខ្មែរ ភាសាវៀតណាម និងភាសាអង់គ្លេស ហើយភាសាទាំងបីមានតម្លៃស្មើគ្នាខាងផ្លូវច្បាប់។

ក្នុងការណីមានការបកស្រាយមិនស្របគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកជាភាសាគោល។

| | |
|---|---|
| តាងនាមរាជរដ្ឋាភិបាលនៃ<br>ព្រះរាជាណាចក្រកម្ពុជា | តាងនាមរដ្ឋាភិបាលនៃ<br>សាធារណៈរដ្ឋសង្គមនិយមវៀតណាម |
| **ហាច ម៉ុនសែ**<br>**រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច**<br>**អតីតយុទ្ធជន និងយុវនីតិសម្បទា** | **ឡេ ថេ ទៀម**<br>**អនុរដ្ឋមន្ត្រីក្រសួងសុខាភិបាលសាធារណៈ** |